# ស្ថានភាពអតិផរណានៅខែតុលា ឆ្នាំ២០១៧

## ក/ អតិផរណាក្នុងប្រទេស

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញក្នុងខែតុលា ឆ្នាំ២០១៧ បានថយចុះក្នុងអត្រា **0,២%** ធៀបនឹងខែមុន ប៉ុន្តែកើនឡើង **២,១%** បើធៀបនឹង១២ខែមុន។

ក្នុងខែតុលានេះ សន្ទស្សន៍ថ្លៃក្រុមទំនិញភាគច្រើនមានការថយចុះគួរឱ្យកត់សម្គាល់ធៀបនឹងខែកញ្ញាកន្លងទៅ ដូចជា សន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង, សន្ទស្សន៍ថ្លៃសម្លៀកបំពាក់និងស្បែកជើង, សន្ទស្សន៍ថ្លៃគមនាគមន៍, និងសន្ទស្សន៍ថ្លៃអប់រំ លើកលែងតែសន្ទស្សន៍ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ និងសន្ទស្សន៍ថ្លៃភោជនីយដ្ឋាន មានការកើនឡើង 0,៥% ដូចគ្នា និងសន្ទស្សន៍ថ្លៃដឹកជញ្ជូនកើនឡើង 0,២%។

បើធៀបនឹងខែដូចគ្នាឆ្នាំមុន សន្ទស្សន៍ថ្លៃក្រុមទំនិញមួយចំនួនមានការកើនឡើង ដូចជាសន្ទស្សន៍ថ្លៃភោជនីយដ្ឋាន, សន្ទស្សន៍ថ្លៃដឹកជញ្ជូន, សន្ទស្សន៍ថ្លៃសម្លៀកបំពាក់និងស្បែកជើង, សន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង, និងសន្ទស្សន៍ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់។ សន្ទស្សន៍ថ្លៃដឹកជញ្ជូនបានកើនឡើងក្នុងអត្រា ៣,៧% ដែលកំណើននេះមានការថមថយមកវិញបន្តិចបើធៀបនឹងកំណើនក្នុងខែសីហា និងកញ្ញាកន្លងទៅ ក្នុងនោះ ថ្លៃប្រេងសាំងធម្មតា និងម៉ាស៊ូត នៅតែបន្តកើនឡើងក្នុងអត្រា ៧,៦% និង៧,២% រៀងគ្នា ស្របពេលនឹងការកើនឡើងថ្លៃប្រេងឆៅ លើទីផ្សារអន្តរជាតិផងដែរ។

តាមការធ្វើចំណោលគិតដល់ត្រឹមខែធ្នូ ឆ្នាំ២០១៧ អតិផរណាប្រចាំឆ្នាំ (year on year) អាចនឹងមានអត្រា ១,៤% ឬ អតិផរណាមធ្យមប្រចាំឆ្នាំ (year average) អាចនឹងមានអត្រា ២,៨%។

**តារាង ១÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម (%)**

| | **ធៀបនឹងខែមុន** | **ធៀបនឹង១ឆ្នាំមុន** |
|---|---|---|
| **មុខទំនិញគ្រប់មុខ** | **-0,២** | **+២,១** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | -0,៤ | +១,៩ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | +0,៥ | +១,៧ |
| ៣-សម្លៀកបំពាក់និងស្បែកជើង | -0,២ | +២,៨ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន | +0,២ | +0,២ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ | -0,១ | +0,៣ |
| ៦-សុខាភិបាល | 0,0 | +១,៣ |
| ៧-ការដឹកជញ្ជូន | +0,២ | +៣,៧ |
| ៨-គមនាគមន៍ | -0,៤ | -0,២ |
| ៩-ការកំសាន្ត និងវប្បធម៌ | -0,១ | -0,៩ |
| ១0-ការសិក្សា | -0,៧ | -0,៧ |
| ១១-ភោជនីយដ្ឋាន | +0,៥ | +៧,២ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | -0,៣ | +១,៤ |

| តារាង ២ ÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ (%) | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបខែមុន | | | ធៀបនឹងឆ្នាំមុន | | |
| | ២០១៧ | | | ២០១៧ | | |
| | សីហា | កញ្ញា | តុលា | សីហា | កញ្ញា | តុលា |
| អង្ករ | +០,២ | +០,២ | +០,១ | +១,៩ | +២,០ | +២,២ |
| សាច់គោ | +១,២ | +០,៧ | -០,១ | +២,៤ | +២,៨ | +២,៤ |
| សាច់មាន់ | +១,១ | -០,១ | +០,៤ | +២,៥ | +១,៨ | +១,២ |
| សាច់ទា | +១,៤ | -០,៨ | +០,៦ | +១,៣ | -០,១ | +០,៧ |
| សាច់ជ្រូក | +០,៣ | +០,១ | -០,៧ | +១,០ | +១,០ | +០,៥ |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | +០,១ | +១,៩ | -០,៨ | +៤,៨ | +៥,៨ | +៤,៣ |
| ក្នុងនោះត្រីស្រស់ | -០,២ | +២,២ | -១,១ | +៥,០ | +៦,០ | +៤,១ |
| ផ្លែឈើ | -០,៣ | ០,០ | ០,០ | +១,៥ | +០,៦ | ០,០ |
| ផ្លែឈើស្រស់ | -០,៧ | ០,០ | ០,០ | +១,១ | ០,០ | -០,៨ |
| បន្លែ | +១,១ | ០,០ | -០,៩ | +៣,៦ | +២,៩ | -០,១ |
| បន្លែជាស្លឹក | +០,៨ | -០,៦ | -១,៣ | +៤,១ | +៣,៤ | -១,៣ |
| បន្លែជាផ្លែ | +២,៣ | -០,៦ | -០,១ | +១,៤ | -០,៨ | -១,៩ |

## ១/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

| តារាង៣÷ អតិផរណាប្រចាំឆ្នាំ (គិតជា %) | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេស | ២០១៦ | ២០១៧ | | | | | | | | |
| | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា |
| ប្រទេសកម្ពុជា | 3.9 | 4.4 | 4.0 | 4.3 | 3.2 | 2.5 | 2.3 | 2.3 | 2.6 | 2.7 | 2.1 |
| ប្រទេសវៀតណាម | 4.74 | 5.2 | 5.0 | 4.7 | 4.3 | 3.2 | 2.5 | 2.5 | 3.4 | 3.4 | 3.0 |
| ប្រទេសថៃ | 1.13 | 1.6 | 1.4 | 0.8 | 0.4 | -0.04 | -0.05 | 0.2 | 0.3 | 0.9 | 0.9 |
| ប្រទេសម៉ាឡេស៊ី | 1.8 | 3.2 | 4.5 | 5.1 | 4.4 | 3.9 | 3.6 | 3.2 | 3.7 | 4.3 | 3.7 |
| ប្រទេសឥណ្ឌូនេស៊ី | 3.02 | 3.5 | 3.8 | 3.6 | 4.2 | 4.3 | 4.4 | 3.9 | 3.8 | 3.7 | 3.6 |
| ប្រទេសហ្វីលីពីន | 2.6 | 2.7 | 3.3 | 3.4 | 3.4 | 3.1 | 2.8 | 2.8 | 3.1 | 3.4 | 3.5 |
| ប្រទេសចិន | 2.1 | 2.5 | 0.8 | 0.9 | 1.2 | 1.5 | 1.5 | 1.4 | 1.8 | 1.6 | 1.9 |
| ប្រទេសកូរ៉េខាងត្បូង | 1.3 | 2.0 | 1.9 | 2.2 | 1.9 | 2.0 | 1.9 | 2.2 | 2.6 | 2.1 | 1.8 |
| ប្រទេសជប៉ុន | 0.3 | 0.4 | 0.3 | 0.2 | 0.4 | 0.4 | 0.4 | 0.4 | 0.7 | 0.7 | 0.2 |

ប្រភពទិន្នន័យ

(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)

(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

**<u>កំណត់សម្គាល់</u>**

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្ត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

***រៀបចំនិងធ្វើចំណោលដោយ***

***នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច***

***អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ***